**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៤៣.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.៩៥៩ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឆែប ខេត្តព្រះវិហារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

www.pheakdeylaw.com

យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ៨.៩៥៩ ( ប្រាំបីពាន់ប្រាំបួនរយហាសិបប្រាំបួន) ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំម្លូព្រៃមួយ ឃុំឆែបមួយ ឃុំឆែបពីរ និងឃុំសង្កែមួយ ស្រុកឆែប ខេត្តព្រះវិហារ ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ អាកាស្យា និងអំពៅ ដូចមានក្នុងផែនទី និងនិយាមការលេខ ៣១៧ចណលផ ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១១ របស់សាលាខេត្តព្រះវិហារ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

បណ្ណាគារ ភក្តីឡង់
PheakdeyLaw Book Store

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

## ផែនទី ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហេង យូ(ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីតធីត ស្ថិតនៅក្នុង ឃុំផ្នុំទ្រាមួយ ឃុំនែបមួយ ឃុំនែបពីរ និងឃុំសង្កែមួយ ស្រុករវៀង ខេត្តព្រះវិហារ




សញ្ញាសំគាល់ :

- ព្រំប្រទល់សម្បទានដីសេដ្ឋកិច្ច
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ឃុំ
- ផ្លូវទឹក
- ផ្លូវ
- សហគមន៍ព្រៃឈើ
- ព្រៃត្រូវរក្សាទុកបន្ថែមទៀត
- ដីភូមិប្រជាពលរដ្ឋ
- ព្រៃការពារប្រភពទឹក

ផ្ទៃដីសរុប: ១៣ ១៤០ហ.ត

ផ្ទៃដីកាត់ចេញ :

| | |
|---|---|
| សហគមន៍ព្រៃឈើ | ១ ៥០៨ ហ.ត |
| ព្រៃត្រូវរក្សាទុកបន្ថែមទៀត | ៤៥២ ហ.ត |
| ព្រៃការពារប្រភពទឹក | ៥១៥ហ.ត |
| ដីកាន់កាប់ប្រជាពលរដ្ឋ | ១ ៣០២ហ.ត |

ផ្ទៃដីកាត់ចេញសរុប : ៤ ១៨១ ហ.ត

ផ្ទៃដីមិនកាត់ចេញ : ៨ ៩៥៩ ហ.ត

COORDINATE SYSTEM
Projection: UTM
Zone: 48
Horizontal Datum: Indian 1960
Spheroid: Everest
UTM Grid: 2 Km

មាត្រដ្ឋាន 1 : 900 000

2 0 2 Km

គំរបព្រៃឆ្នាំ២០០៦ :

| | |
|---|---|
| ព្រៃស្រោង | ២៣ហ.ត |
| ព្រៃពាក់កណ្តាលស្រោង | ២ ៣៥០ហ.ត |
| ព្រៃល្បោះ | ១០ ១៨៥ហ.ត |
| ដីគ្មានគំរបព្រៃ | ៥៨២ហ.ត |
| សរុប : | ១៣ ១៤០ ហ.ត |

និយាមការ ព្រំប្រទល់ :

| Coor_x | Coor_y | |
|---|---|---|
| 532945 | 1525324 | 1 |
| 532945 | 1526124 | 2 |
| 534500 | 1526124 | 3 |
| 534500 | 1525324 | 4 |
| 541395 | 1525574 | 5 |
| 541114 | 1526968 | 6 |
| 542270 | 1526968 | 7 |
| 556582 | 1529378 | 8 |
| 556671 | 1528325 | 9 |
| 555936 | 1528325 | 10 |
| 555746 | 1528531 | 11 |
| 555836 | 1529377 | 12 |
| 541890 | 1526268 | 13 |
| 544763 | 1526098 | 14 |
| 542378 | 1526968 | 15 |
| 544355 | 1525592 | 16 |
| 541115 | 1526969 | A1 |
| 534500 | 1526969 | A2 |
| 534500 | 1524293 | A3 |
| 541660 | 1524271 | A4 |
| 536522 | 1521177 | H1 |
| 538010 | 1521271 | H2 |

បានឃើញ និង ឯកភាព
សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច

បានឃើញ និង ឯកភាព
សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច

បានឃើញ និង ឯកភាព
សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច

បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច

បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច

បានឃើញ និង ឯកភាព
សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច

បានឃើញ និងឯកភាព
គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មេត្តាពិនិត្យ និងសម្រេច
អភិបាលខេត្ត

បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច

ខន ស៊ាន ប៉ិ
អ៊ុំ មាំរ៉ា
លី.ផ្អែរ៉ា